**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គនាយកដ្ឋានកសិកម្ម**

លេខ...១០៣៦......អ.ន.ក

ថ្ងៃព្រហស្បតិ៍ ៤រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី...២៧...ខែ...មិថុនា...ឆ្នាំ២០១៩

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំខែឧសភាឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបនូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំខែឧសភា ឆ្នាំ២០១៩ មានដូចខាងក្រោម៖

I. **លទ្ធផលបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៩** (គិតត្រឹមថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩)

១. ដំណាំស្រូវ : ផ្ទៃដីស្ទូងព្រោះសរុបអនុវត្តបានចំនួន ៤៨៤.០០៧ ហ.ត ស្មើនឹង១៨,៧២ % នៃផែនការចំនួន ២.៥៨៦.១៥២ ហ.ត យឺតជាងឆ្នាំមុនចំនួន ៣៥០.៨៨៣ ហ.ត

- ការងារភ្ជួររាស់ដី : ផ្ទៃដីភ្ជួររាស់សរុបអនុវត្តបានចំនួន ៧២៧.១៣៧ ហ.ត យឺតជាងឆ្នាំមុនចំនួន ២៦៩.១០៣ ហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តចំនួន ៧២៤.១១៧ ហ.ត ស្មើនឹង៩៩,៥៨%
- ផ្ទៃដីសាបសរុប : ៣០៣ ហ.ត តិចជាងឆ្នាំមុនចំនួន ៣.៣៥៧ ហ.ត







*ក្រាហ្វិក៖ ស្ថិតិផ្ទៃដីភ្ជួររាស់ និងដាំដុះស្រូវរដូវវស្សាពីឆ្នាំ២០១៥-២០១៩ គិតត្រឹម ខែឧសភានៃឆ្នាំ*

តាមក្រាហ្វិកខាងលើបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំដូចគ្នាគិតត្រឹមចុងខែឧសភា ផ្ទៃដីភ្ជួររាស់រដូវវស្សា និងផ្ទៃដីដាំដុះដំណាំស្រូវឆ្នាំនេះអនុវត្តបានលឿនជាងឆ្នាំ២០១៥ ,២០១៦ និងឆ្នាំ២០១៧ តែយឺតជាងឆ្នាំ២០១៨។

២. ដំណាំរួមផ្សំ : អនុវត្តបានចំនួន ១៤.១០២ ហ.ត យឺតជាងឆ្នាំមុនចំនួន ១១.៨១៩ ហ.ត។

៣. ដំណាំឧស្សាហកម្ម : អនុវត្តបានចំនួន ២៥៨.៤៣៩ ហ.ត តិចជាងឆ្នាំមុនចំនួន ១៥៦.៦៣៤ ហ.ត។



អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427